YUNNAN DAILY PRESS GROUP
云南日报报业集团
No.207

ប្រទេសចិន-ខេត្តយូនណាន

ទស្សនាប្រចាំថ្ងៃ

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី28លេខ8119 ថ្ងៃសុក្រ ទី03 ខែមករា ឆ្នាំ2020

ឆ្នាំ២០២០ បង្កើតសង្គមធូរធារគ្រប់ជ្រុងជ្រោយអ្នកណាក៏មិនអាចខ្វះបានទេ

ប្រជាជនច្រៀងចម្រៀងនិងរាំរាំនៅភូមិស៊ីធានឃុំ លាំងសាន ស្រុកស៊ីនឌីងក្រុងសាវយ៉ាង ខេត្តហ្គីណាន ដើម្បីអបអរសាទរការ ប្រមូលបានផលក្រូចដ៏ច្រើន

-កាលពីថ្ងៃទី១០ ដល់ទី១២ ខែធ្នូ ឆ្នាំ២០១៩ កិច្ចប្រជុំការងារសេដ្ឋកិច្ចមជ្ឈិមបក្សកុម្មុយនិស្តចិនបានប្រារព្ធនៅក្រុងប៉េកាំង ។ អង្គប្រជុំបានបូកសរុបដោយផ្តិតផ្តង់នូវការងារសេដ្ឋកិច្ចប្រចាំឆ្នាំ២០១៩ធ្វើការវិភាគយ៉ាងស៊ីជម្រៅអំពីស្ថានការណ៍សេដ្ឋកិច្ចនាពេលបច្ចុប្បន្ននិងចាត់ចែងការងារសេដ្ឋកិច្ចនៅឆ្នាំ២០២០ ។ ឆ្នាំ ២០២០ជាឆ្នាំចុងក្រោយនៃផែនការកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយ ។ ឈរលើគោលដៅដែលមានលក្ខណៈជាប្រវត្តិសាស្ត្រនេះតើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចចិននឹងអាចបង្ហាញពីនិន្នាការអភិវឌ្ឍន៍អ្វីខ្លះ?មានការងារសំខាន់អ្វីខ្លះ?កាសែតយើងខ្ញុំនឹងចុះផ្សាយនូវអត្ថបទអំពីបញ្ហានេះជាបន្តបន្ទាប់ដើម្បីផ្តល់ព័ត៌មានដល់មិត្តអ្នកអាន ។

តើអ្វីហៅថា"សង្គមធូរធារ"?ពាក្យថា"ធូរធារ"គឺជាគំនិតរបស់ជនជាតិចិនសម្រាប់ពិពណ៌នាអំពីសង្គមល្អបវរ ។ ក្នុងគំនិតទស្សនៈរបស់ជនជាតិចិនពាក្យនេះតំណាងឱ្យភាពសម្បូរបែបនិងអាចបង្ហាញពីគោលដៅនៃការស្វែងរកជីវភាពរស់នៅដែលប្រកបដោយសុភមង្គល ។ តើអ្វីហៅថា"ធូរធារគ្រប់ជ្រុងជ្រោយ"?បើសិនជាពាក្យ"ធូរធារ"ចង្អុលសំដៅលើកម្រិតថ្នាក់នៃការអភិវឌ្ឍន៍នោះពាក្យ"គ្រប់ជ្រុងជ្រោយ"គឺតំណាងឱ្យការថែរក្សាតុល្យភាពលក្ខណៈចុះសម្រុងគ្នានិងនិរន្តរភាព ។

នៅឆ្នាំ២០២០ ការងារសេដ្ឋកិច្ច ចិននឹងត្រូវធ្វើឡើងដោយអាស្រ័យលើគោលដៅនិងភារកិច្ចដែលមានពាក់ព័ន្ធនឹងការបង្កើតសង្គមធូរធារគ្រប់ជ្រុងជ្រោយ។

ភាគីចិនមានជំនឿចិត្តដ៏រឹងមាំក្នុងការសម្រេចនូវគោលដៅនេះតាមពេលកំណត់ ។ លោក នីវ លីអនុប្រធានផ្នែកព្យាករសេដ្ឋកិច្ចនៃមជ្ឈមណ្ឌលព័ត៌មានជាតិចិនបានប្រាប់អ្នកកាសែតថាតាមលទ្ធផលសិក្សាជាទូទៅអំពីស្ថានភាពសេដ្ឋកិច្ចទូទាំងប្រទេសចិនលើកទី៤ បានឱ្យដឹងថា បើសិនជាប្រទេសចិនអាចរក្សាកំណើនសេដ្ឋកិច្ច៦ភាគរយនៅឆ្នាំ២០២០ ក៏អាចសម្រេចនូវគោលដៅដែលទំហំសេដ្ឋកិច្ចសរុបកើនឡើងទ្វេដង។យើងអាចសម្រេចបាននូវគោលដៅនេះ។ ប្រទេសចិនមិនគ្រាន់តែត្រូវសម្រេចគោលដៅអំពីកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ អ្វីដែលសំខាន់ជាងនេះទៅទៀត គឺត្រូវធ្វើឱ្យប្រជាជនទទួលបានផលប្រយោជន៍កាន់តែច្រើនមានការរស់នៅកាន់តែមានសុភមង្គលនិងមានអារម្មណ៍សុវត្ថិភាពផ្ទាល់ខ្លួន។ភាគីចិននឹងលើកកម្ពស់អនុវត្តគោលនយោបាយនេះ។ លោកបានបន្តែមទៀតថា "សព្វថ្ងៃខ្ញុំបានបង្កើតក្រុមសុខាភិបាលមួយ។ ក្នុងក្រុមនេះមានគ្រូពេទ្យព្យាបាលជំងឺភ្នែកៗរូប។ យើងអាចចុះទៅតំបន់ជនបទ ដើម្បីជួយពិនិត្យសុខភាពភ្នែករបស់អ្នកស្រុកដោយផ្ទាល់ខ្លួន។ យើងបានទទួលបរិក្ខារពេទ្យថ្មីដែលផ្តល់ការងាយស្រួលដ៏ច្រើនក្នុងការពិនិត្យជំងឺឱ្យអ្នកស្រុក។ ក្រោយពីអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រតាមរយៈការអនុវត្តគម្រោងសុខាភិបាលមានគ្រូពេទ្យអ្នើមដ៏ច្រើន ដែលមកពីក្រុងស្បៃងហៃ និងមន្ទីរពេទ្យថ្នាក់ខេត្តមកធ្វើការនៅទីនេះ។ បច្ចេកទេសរបស់គ្រូពេទ្យក្នុងមន្ទីរពេទ្យថ្នាក់ស្រុកក៏បានត្រូវលើកកម្ពស់ជាបន្តបន្ទាប់ដែរ។ គោលនយោបាយកាត់បន្ថយភាពក្រីក្របានធ្វើឱ្យតំបន់ជនបទប្រែមុខប្រែមាត់យ៉ាងខ្លាំង៕

ដោយស្បុង យ៉ានឈូ កុងហ្គលីហ៊ុងឈាំង និង លី វិនជួន

ឯកឧត្តម ស៊ី ជីនភីង បកស្រាយពីការខិតខំដោះស្រាយបញ្ហាលេចធ្លោដែលទទួលការចាប់អារម្មណ៍ជាទូទៅពីសំណាក់ប្រជាជន

អំពីការរក្សាកំណើនសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចចំណុចគ្រឹះ គឺត្រូវខិតខំដោះស្រាយបញ្ហាលេចធ្លោដែលទទួលការចាប់អារម្មណ៍ជាទូទៅពីសំណាក់ប្រជាជន។ជំរុញការកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយដោយឈរលើមូលដ្ឋាននៃការដោះស្រាយបញ្ហាលេចធ្លោដែលទទួលការចាប់អារម្មណ៍ជាទូទៅពីសំណាក់ប្រជាជនស្របទៅនឹងសំណូមពរនៃការធ្វើកំណែទម្រង់រចនាសម្ព័ន្ធផ្នែកផ្គត់ផ្គង់ហើយនឹងបង្កលក្ខណៈងាយស្រួលសម្រាប់ការបង្កើតចំណុចកំណើនសេដ្ឋកិច្ចថ្មីនិងបង្កើនសក្តានុពលសម្រាប់ការអភិវឌ្ឍរយៈពេលវែងចំណែកចំណុចកំណើនសេដ្ឋកិច្ចថ្មី គឺត្រូវបង្កប់នៅក្នុងការងារដោះស្រាយបញ្ហាលេចធ្លោដែលទទួលការចាប់អារម្មណ៍ជាទូទៅពីសំណាក់ប្រជាជន ៕

(ដកស្រង់ចេញពីសុន្ទរកថារបស់ឯកឧត្តមស៊ី ជីនភីងក្នុងកិច្ចប្រជុំលើកទី៥នៃក្រុមដឹកនាំហិរញ្ញវត្ថុមជ្ឈិមបក្សកុម្មុយនិស្តចិននៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៦)

ការចងចាំផ្នែកវប្បធម៌នៃចម្លាក់លើស្រុកជីនឈួន

ទេសចរកំពុងទស្សនា ស្នាដៃចម្លាក់ឈើស្រុកជីនឈួន

ឧបករណ៍កសិកម្ម និងគ្រឿងឈើ ដែលត្រូវបានជីករកឃើញនៅឃុំហាយមិនខ្វះ ស្រុកជីនឈួន មានអាយុកាលជាង៥៣០០ឆ្នាំហើយ។ នេះបានបង្ហាញឱ្យឃើញពីប្រភពដើមនៃចម្លាក់ឈើស្រុកជីនឈួន។ តាមកំណត់ត្រាប្រវត្តិសាស្ត្រ និងលទ្ធផលសិក្សាស្រាវជ្រាវរបស់អ្នកជំនាញការបានឱ្យដឹងថា នៅសម័យថាង និងសុងនៃប្រទេសចិន សិប្បកម្មចម្លាក់ឈើស្រុកជីនឈួនបានឈានដល់កម្រិតខ្ពស់និងមានឈ្មោះល្បីល្បាញហើយ។ ឆ្លងតាមដំណើរអភិវឌ្ឍន៍រយៈពេលយ៉ាងវែង ចម្លាក់ឈើស្រុកជីនឈួន បានក្លាយទៅជាសិប្បកម្មចម្លាក់ឈើជនជាតិភាគតិចដែលមានលក្ខណៈតំណាងពិសេសក្នុងតំបន់និរតីចិន។

ប៉ុន្មានឆ្នាំមកនេះ គម្រោងថែរក្សា និងផ្សព្វផ្សាយសិប្បកម្មចម្លាក់ឈើស្រុកជីនឈួន បានទទួលសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់។ ស្នាដៃចម្លាក់ឈើស្រុកជីនឈួន តែងតែទទួលរង្វាន់ថ្នាក់ជាតិ និងត្រូវដាក់តាំងពិព័រណ៍នៅក្រៅប្រទេសចិន។ មណ្ឌលសូយ័តជនជាតិតៃតាលី ខេត្តយូនណាន បានបង្កើតមជ្ឈមណ្ឌលទទួលបន្តនិងផ្សព្វផ្សាយពីសិប្បកម្មចម្លាក់ឈើមួយចំនួនដែលបានផ្តល់ឱកាសថ្មីសម្រាប់ការអភិវឌ្ឍនៃសិប្បកម្មប្រពៃណីនេះក្នុងសម័យទំនើប៕ **ដោយឈីនម៉ុងលីន**

គ្រូពេទ្យដែលធ្វើដំណើរតាមផ្លូវជាប់រហូតជាប់ចិត្តនឹងអ្នកស្រុកនៅស្រុកកំណើតរបស់ខ្លួន

លោក ឃួ ឆាវឈីង កំពុងពិនិត្យសុខភាពឱ្យអ្នកស្រុកក្នុងតំបន់

ពេលថ្មីៗនេះ នៅពេលទៅយកបទសម្ភាសន៍នៅមន្ទីរពេទ្យប្រជាជនក្នុងស្រុកស្វយ័តជនជាតិលីស៊ូវីស៊ីមណ្ឌលស្វយ័តជនជាតិទីបេត៍ទីឈីង ខេត្តយូនណាន អ្នកកាសែតបានជួបនឹងលោកឃួ ឆាវឈីង ដែលជាអនុប្រធានមន្ទីរពេទ្យប្រធានផ្នែកព្យាបាលជំងឺត្រចៀកច្រមុះ និងបំពង់កនិងជាអ្នកជំនាញការព្យាលបាលជំងឺភ្នែក ។ លោកមានការងាររវល់ខ្លាំងណាស់ហាក់ដូចជាគ្រូពេទ្យម្នាក់ដែលតែងតែធ្វើដំណើរតាមផ្លូវជាប់រហូតមើលទៅ ។

លោកបានប្រាប់អ្នកកាសែតថា "នៅឆ្នាំ២០០២ ខ្ញុំបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវេជ្ជសាស្ត្រក្រុងគុនមីង ហើយត្រឡប់មកស្រុកកំណើតខ្ញុំវិញ ដើម្បីធ្វើការនៅមន្ទីរពេទ្យប្រជាជនស្រុកវីស៊ុ។ ខ្ញុំសម្រេចចិត្តមកធ្វើការនៅស្រុកកំណើតរបស់ខ្ញុំដោយសារខ្ញុំចង់ប្រើចំណេះដឹងពេទ្យដែលខ្ញុំបានរៀនសូត្រទៅជួយដល់អ្នកស្រុកដែលមានតម្រូវការ។ លោកជាគ្រូពេទ្យល្អម្នាក់ដែលមិនត្រឹមតែធ្វើការនៅក្នុងមន្ទីរពេទ្យប៉ុណ្ណោះទេ ហើយតែងតែទៅធ្វើការនៅស្រែចម្ការផងៗ"

នៅឆ្នាំ២០០៧ លោកបានចូលរួមកម្មវិធីសប្បុរសធម៌មួយដែលរៀបចំដោយសមាគមជនពិការ។ កាលនោះលោកបានរកឃើញថា នៅតំបន់ជនបទមានអ្នកស្រុកច្រើនកើតជំងឺភ្នែកឡើងបាយ។ លោកយល់ឃើញថា ដោយសារគ្រូពេទ្យធ្វើការមិនបានជិតដល់ទើបធ្វើឱ្យប្រជាជនច្រើនរងគ្រោះពីជំងឺនេះ។ លោកបានប្រាប់អ្នកកាសែតថា នេះជាកំហុសរបស់ខ្ញុំ ពីព្រោះខ្ញុំធ្វើការងារមិនបានល្អទេ។ លោកបន្ទោសខ្លួនក្នុងចិត្តហើយចាប់ផ្តើមកំណត់ផែនការដ៏ធំមួយដើម្បីជួយប្រជាជនក្នុងតំបន់ជនបទ។

តាំងពីពាក់កណ្តាលឆ្នាំ២០០៨ មក លោកតែងតែស្ពាយកាបូបទៅធ្វើការសិក្សានៅតំបន់ជុំវិញរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដើម្បីជួយពិនិត្យសុខភាពភ្នែករបស់អ្នកស្រុកក្នុងតំបន់។ លោកបានគូសបញ្ជាក់ថា នៅឆ្នាំនោះខ្ញុំបានធ្វើការវះកាត់ឱ្យអ្នកស្រុកជាង៧០នាក់ ។ ខ្ញុំនឿយហត់ខ្លាំងតែសប្បាយចិត្តណាស់ ។ ខ្ញុំគិតថា អ្វីដែលខ្ញុំបានធ្វើទាំងនោះពិតជាមានតម្លៃណាស់!

ពេលដំបូងលោកទៅជួយព្យាបាលជំងឺរបស់អ្នកស្រុកតែម្នាក់ឯងទេ តែសព្វថ្ងៃលោកបានបង្កើតជាក្រុមសុខាភិបាលជំនាញមួយ។ លោកចាប់អារម្មណ៍ឃ្យាងខ្លាំងចំពោះគោលនយោបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសពិសេសគឺចំពោះការកែចម្រើននៃតំបន់ជនបទក្រោយពីបានអនុវត្តគោលនយោបាយនេះ។ លោកបានបន្តែមទៀតថា "សព្វថ្ងៃខ្ញុំបានបង្កើតក្រុមសុខាភិបាលមួយ។ ក្នុងក្រុមនេះមានគ្រូពេទ្យព្យាបាលជំងឺភ្នែក៧រូប។ យើងអាចចុះទៅតំបន់ជនបទ ដើម្បីជួយពិនិត្យសុខភាពភ្នែករបស់អ្នកស្រុកដោយផ្ទាល់ខ្លួន។ យើងបានទទួលបរិក្ខារពេទ្យថ្មីដែលផ្តល់ការងាយស្រួលដ៏ច្រើនក្នុងការពិនិត្យជំងឺឱ្យអ្នកស្រុក។ ក្រោយពីអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រតាមរយៈការអនុវត្តគម្រោងសុខាភិបាលមានគ្រូពេទ្យអ្នើមដ៏ច្រើន ដែលមកពីក្រុងស្បៃងហៃ និងមន្ទីរពេទ្យថ្នាក់ខេត្តមកធ្វើការនៅទីនេះ។ បច្ចេកទេសរបស់គ្រូពេទ្យក្នុងមន្ទីរពេទ្យថ្នាក់ស្រុកក៏បានត្រូវលើកកម្ពស់ជាបន្តបន្ទាប់ដែរ។ គោលនយោបាយកាត់បន្ថយភាពក្រីក្របានធ្វើឱ្យតំបន់ជនបទប្រែមុខប្រែមាត់យ៉ាងខ្លាំង៕

ដោយស្បុង យ៉ានឈូ កុងហ្គលីហ៊ុងឈាំង និង លី វិនជួន

ហាត់កីឡាពិសេសដ៏ទាក់ទាញចំណាត់ឡើងយ៉ាងសប្បាយរីករាយ

ពេលថ្មីៗនេះ សិស្សានុសិស្សនៃសាលាបឋមសិក្សា ជីនតែវ៉ាន ឃុំតាស្ងួយជីង ស្រុកលួងភីង ក្រុងឈូជីង ខេត្តយូនណាន បានទៅសម្តែងកម្មវិធីក្បាច់គុនធ្នើតនៅលើឆាកសម្តែងធ្វើពីកញ្ចក់នៅក្បែរសាលារៀន។ សាលាបឋមសិក្សាជីនតែវ៉ាន បានដាក់បញ្ចូលនូវកម្មវិធីកីឡាប្រពៃណីមួយចំនួនទៅក្នុងកម្មវិធីអប់រំកីឡា ហើយរៀបចំឱ្យសិស្សានុសិស្សចូលរួមកម្មវិធីកីឡាពិសេស ដើម្បីបណ្តុះបណ្តាលសិស្សឱ្យមានស្មារតីសហប្រតិបត្តិការ៕

ដោយម៉ៅ ហុង (កាសែត ប្រជាជនដេលី)